CAT®

M0088349 (KM)
ខែធ្នូ ឆ្នាំ 2017

# សៀវភៅណែនាំស្តីពីប្រតិបត្តិការ និងការថែទាំជួសជុល

## ប្រព័ន្ធ Product Link® PL042 និង PLE702

PL7 1-UP (ផលិតផលគ្រប់គ្រងគ្រឿងចក្រ និង ការណែនាំ)

i06558969

# ព័ត៌មានអំពីសុវត្ថិភាពសំខាន់ៗ

គ្រោះថ្នាក់ភាគច្រើនដែលពាក់ព័ន្ធនឹងប្រតិបត្តិការគ្រឿងចក្រ ការថែទាំ និងការជួសជុល គឺបណ្ដាលមកពីការមិនគោរពវិធានសុវត្ថិភាពជាមូលដ្ឋាន ឬការប្រុងប្រយ័ត្នជាមុនៗ ជារឿយៗ គ្រោះថ្នាក់អាចជៀសវាងបានតាមរយៈការដឹងពីស្ថានភាពដែលអាចបង្កគ្រោះថ្នាក់ មុនពេលគ្រោះថ្នាក់កើតឡើងៗ មនុស្សម្នាក់ៗត្រូវប្រយ័ត្នចំពោះមុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតមាន រួមមានកត្តាមនុស្សដែលអាចប៉ះពាល់ដល់សុវត្ថិភាពៗ លើសពីនេះទៀត មនុស្សម្នាក់នេះក៏គួរមានការបណ្ដុះបណ្ដាលជំនាញ និងមានឧបករណ៍ដែលចាំបាច់ ដើម្បីបំពេញមុខងារទាំងនេះឲ្យបានត្រឹមត្រូវផងដែរៗ

**ប្រតិបត្តិការ ការដាក់ប្រេងរំអិល ការថែទាំ ឬការជួសជុលគ្រឿងចក្រមិនបានត្រឹមត្រូវ អាចបង្កគ្រោះថ្នាក់ ហើយអាចបណ្ដាលឲ្យមានរបួស ឬស្លាប់ៗ**

**មិនត្រូវធ្វើប្រតិបត្តិការ ឬធ្វើការដាក់ប្រេងរំអិល ការថែទាំ ឬការជួសជុលចំពោះគ្រឿងចក្រនេះឡើយ រហូតដល់អ្នកបញ្ជាក់ថា អ្នកត្រូវបានអនុញ្ញាតឲ្យអនុវត្តការងារនេះ ហើយបានអាននិងយល់ពីព័ត៌មានអំពីប្រតិបត្តិការ ការដាក់ប្រេងរំអិល ការថែទាំ និងការជួសជុលៗ**

ការប្រុងប្រយ័ត្ន និងការព្រមានជាមុនអំពីបញ្ហាសុវត្ថិភាព ត្រូវបានផ្ដល់នៅក្នុងកូនសៀវភៅណែនាំ និងនៅលើគ្រឿងចក្រៗ ប្រសិនបើមិនយកចិត្តទុកដាក់ចំពោះការព្រមានអំពីគ្រោះថ្នាក់ទាំងនេះ របួសរាងកាយ ឬស្លាប់អាចនឹងកើតមានឡើងចំពោះអ្នក ឬអ្នកដទៃៗ

គ្រោះថ្នាក់នានាត្រូវបានសម្គាល់ដោយ "និមិត្តសញ្ញាឲ្យប្រយ័ត្នអំពីសុវត្ថិភាព" អមដោយ "ពាក្យជាសញ្ញា" ដូចជា "DANGER" (គ្រោះថ្នាក់), "WARNING" (ការព្រមាន) ឬ "CAUTION" (ការប្រុងប្រយ័ត្ន)ៗ ស្លាក "WARNING" (ការព្រមាន) ឲ្យប្រយ័ត្នអំពីសុវត្ថិភាព ត្រូវបានបង្ហាញខាងក្រោមៗ

**⚠ ការព្រមានប្រាប់**

អត្ថន័យនៃនិមិត្តសញ្ញាឲ្យប្រយ័ត្នអំពីសុវត្ថិភាពនេះមានដូចខាងក្រោម៖

**ប្រយ័ត្ន! សូមប្រយ័ត្ន! អាចប៉ះពាល់សុវត្ថិភាពរបស់អ្នកៗ**

សារដែលលេចឡើងក្រោមការព្រមាន ពន្យល់អំពីគ្រោះថ្នាក់ ហើយអាចជាសំណេរ ឬជារូបភាពៗ

បញ្ជីប្រតិបត្តិការតូចមួយដែលអាចបណ្ដាលឲ្យគ្រឿងចក្រខូចត្រូវបានកំណត់សញ្ញាណតាមស្លាក "កំណត់ចំណាំ" នានា ដែលមាននៅលើគ្រឿងចក្រ និងឯកសារបោះពុម្ពផ្សាយនេះៗ

**Caterpillar មិនអាចរៀបរាប់អស់អំពីស្ថានភាពដែលអាចបង្កគ្រោះថ្នាក់ទាំងអស់បានឡើយៗ ដូចនេះ ការព្រមាននៅក្នុងឯកសារបោះពុម្ពផ្សាយនេះ និងការព្រមាននៅលើគ្រឿងចក្រ មិនបានរួមបញ្ចូលគ្រប់ស្ថានភាពទាំងអស់ទេៗ អ្នកមិនត្រូវប្រើគ្រឿងចក្រនេះតាមវិធីណាមួយខុសពីអ្វីដែលបានណែនាំនៅក្នុងកូនសៀវភៅណែនាំនេះឡើយ លុះត្រាតែអ្នកច្បាស់ក្នុងចិត្តជាមុនថា អ្នកបានគិតពិចារណាលើវិធាន និងការប្រុងប្រយ័ត្នអំពីសុវត្ថិភាពទាំងអស់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការគ្រឿងចក្រនេះនៅទីតាំងប្រើប្រាស់នីមួយៗ រួមទាំងវិធាន និងការប្រុងប្រយ័ត្នអំពីសុវត្ថិភាពនៅតាមទីតាំងជាក់លាក់នៅក្នុងការដ្ឋានៗ ប្រសិនបើឧបករណ៍ ទម្រង់ការ វិធីសាស្ត្រធ្វើការងារ ឬបច្ចេកទេសប្រតិបត្តិការមិនទទួលបានការណែនាំជាក់លាក់ពី Caterpillar ទេ លោកអ្នកត្រូវតែប្រាកដដោយខ្លួនឯងថា វាមានសុវត្ថិភាពចំពោះលោកអ្នក និងអ្នកដទៃៗ លោកអ្នកក៏ត្រូវប្រាកដដែរថា លោកអ្នកត្រូវបានអនុញ្ញាតឲ្យអនុវត្តការងារនេះ ហើយក៏ត្រូវធានាទៀតដែរថា គ្រឿងចក្រនឹងមិនខូច ឬក៏គ្មានសុវត្ថិភាពដោយសារប្រតិបត្តិការ ការដាក់ប្រេងរំអិល ការថែទាំ ឬវិធីជួសជុលដែល លោកអ្នកចង់ធ្វើផងដែរៗ**

ព័ត៌មាន លក្ខណៈបច្ចេកទេស និងរូបភាពនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ គឺជាព័ត៌មានមូលដ្ឋានដែលមាននៅពេលចងក្រងឯកសារបោះពុម្ពផ្សាយៗ លក្ខណៈបច្ចេកទេស តំណឹង សម្ពាធរង្វាស់ ការលៃតម្រូវ រូបភាព និងចំណុចផ្សេងទៀត អាចត្រូវបានផ្លាស់ប្ដូរគ្រប់ពេលវេលាៗ ការផ្លាស់ប្ដូរទាំងនេះអាចប៉ះពាល់ដល់សេវាកម្មគ្រឿងចក្រដែលបានផ្ដល់ជូនៗ សូមស្វែងយល់ឲ្យបានច្បាស់លាស់ និងទទួលយកព័ត៌មានថ្មីៗបំផុត នៅមុនពេលអ្នកចាប់ផ្ដើមការងារណាមួយៗ អ្នកចែកចាយCat មានព័ត៌មានថ្មីៗបំផុតៗ

**⚠ ការព្រមានប្រាប់**

**នៅពេលមានការផ្លាស់ប្ដូរផ្នែកគ្រឿងបន្លាស់សម្រាប់គ្រឿងចក្រនេះ Caterpillar ផ្ដល់អនុសាសន៍ឲ្យប្រើប្រាស់គ្រឿងបន្លាស់របស់ Caterpillarៗ**

**ការមិនធ្វើតាមការព្រមានអាចបណ្ដាលឲ្យផលិតផលខូចមុនអាយុកាលកំណត់ ខូចផលិតផល មានរបួសដល់រាងកាយ ឬអាចបាត់បង់ជីវិតៗ**

---

**នៅសហរដ្ឋអាមេរិក ការថែទាំ ការប្ដូរគ្រឿងបន្លាស់ ឬការជួសជុលឧបករណ៍ និង ប្រព័ន្ធគ្រប់គ្រងការបំភាយផ្សែង អាចធ្វើឡើងដោយគ្រឹះស្ថានជួសជុលណាមួយ ឬបុគ្គលណាម្នាក់តាមការជ្រើសរើសរបស់ម្ចាស់គ្រឿងចក្រៗ**

# តារាងមាតិកា

បុព្វកថា ..... 4

## ផ្នែកសុវត្ថិភាព

សញ្ញា និងស្លាកសញ្ញាសុវត្ថិភាព ..... 5

ព័ត៌មានអំពីគ្រោះថ្នាក់ទូទៅ ..... 6

## ផ្នែកព័ត៌មានផលិតផល

ព័ត៌មានអត្តសញ្ញាណ ..... 7

## ផ្នែកប្រតិបត្តិការ

ប្រតិបត្តិការ..... 14

## ផ្នែកលិបិក្រម

លិបិក្រម..... 16

# បុព្វកថា

## ព័ត៌មាននៃឯកសារ

កូនសៀវភៅណែនាំនេះ គួរតែរក្សាទុកនៅបន្ទប់របស់ប្រតិបត្តិករ នៅកន្លែងទុកដាក់ឯកសារ ឬកន្លែងរក្សាទុកឯកសារនៅខាងក្រោយខ្នងកៅអី។

កូនសៀវភៅណែនាំនេះមានព័ត៌មានអំពីសុវត្ថិភាព ការណែនាំអំពីប្រតិបត្តិការ និងអនុសាសន៍នៃការថែទាំ។

រូបថត ឬរូបភាពខ្លះនៅក្នុងការបោះពុម្ពផ្សាយនេះបង្ហាញព័ត៌មានលម្អិត ឬឯកសារភ្ជាប់ដែលអាចមានលក្ខណៈខុសគ្នាពីផលិតផលរបស់អ្នក។

ការបន្តកែលម្អ និងការវិវឌ្ឍនៃការឌីស្សាញផលិតផលនេះ អាចនឹងបណ្ដាលឲ្យមានការផ្លាស់ប្ដូរចំពោះផលិតផលរបស់អ្នក ដែលមិនមាននៅក្នុងឯកសារបោះពុម្ពផ្សាយនេះ។ សូមអាន ស្វែងយល់ និងរក្សាទុកកូនសៀវភៅណែនាំនេះជាមួយនឹងផលិតផល។

នៅពេលមានសំណួរទាក់ទងនឹងផលិតផលរបស់អ្នក ឬឯកសារបោះពុម្ពផ្សាយនេះ សូមពិគ្រោះជាមួយអ្នកចែកចាយ Cat របស់អ្នកសម្រាប់ព័ត៌មានថ្មីៗបំផុត។

## សុវត្ថិភាព

ផ្នែកសុវត្ថិភាពមានរៀបរាប់អំពីការប្រុងប្រយ័ត្នពីសុវត្ថិភាពសំខាន់ៗ។ លើសពីនេះទៀត ផ្នែកនេះកំណត់ប្រភេទអត្ថបទ និងទីតាំងសញ្ញា និងស្លាកសញ្ញាព្រមានដែលបានប្រើនៅលើគ្រឿងចក្រ។

## ប្រតិបត្តិការ

ផ្នែកប្រតិបត្តិការនេះជាឯកសារយោងសម្រាប់ប្រតិបត្តិករថ្មី និងជាការរំលឹកសម្រាប់ប្រតិបត្តិករដែលមានបទពិសោធន៍។ ផ្នែកនេះរួមមានការពិភាក្សាអំពីឧបករណ៍វាស់កុងតាក់ ឧបករណ៍បញ្ជាផលិតផល ឧបករណ៍បញ្ជាគ្រឿងភ្ជាប់  និងព័ត៌មានអំពីការសរសេរកម្មវិធី។

រូបថត និងរូបភាពណែនាំប្រតិបត្តិករតាមនីតិវិធីត្រឹមត្រូវ នៃការត្រួតពិនិត្យ ការបញ្ឆេះប្រតិបត្តិការ និងការបញ្ឈប់ផលិតផល។

បច្ចេកទេសប្រតិបត្តិការដែលមានក្នុងឯកសារបោះពុម្ពផ្សាយនេះ ជាឯកសារមូលដ្ឋាន។ ជំនាញ និងបច្ចេកទេសកាន់តែរីកចម្រើន នៅពេលប្រតិបត្តិករ កើនចំណេះដឹងផ្នែកផលិតផល និងផ្នែកសមត្ថភាពរបស់ផលិតផល។

## ការថែទាំជួសជុល

ផ្នែកការថែទាំជួសជុលគឺជាការណែនាំសម្រាប់ការថែទាំឧបករណ៍។

# ផ្នែកសុវត្ថិភាព

i07214816

## សញ្ញា និងស្លាកសញ្ញាសុវត្ថិភាព

កូដ SMCS៖ 7606

**ការព្រមានប្រាប់**

ហាមប្រតិបត្តិការ ឬធ្វើការងារលើគ្រឿងចក្រនេះ បើលោកអ្នកមិនបានអាន និងស្វែងយល់អំពីសេចក្តីណែនាំនិងការព្រមាន ដែលមាននៅក្នុងសៀវភៅណែនាំប្រតិបត្តិការ និង ការថែទាំទេនោះ។ ការមិនអនុវត្តតាមសេចក្តីណែនាំ ឬមិនបានយកចិត្តទុកដាក់លើការព្រមានទាំងនេះអាចបណ្តាលឲ្យមានរបួសដល់រាងកាយ ឬស្លាប់បាន។ ទាក់ទងអ្នកចែកចាយ Caterpillar របស់អ្នកជំនួសឲ្យកូនសៀវភៅណែនាំ។ ការយកចិត្តទុកដាក់សមស្របគឺជាការទទួលខុសត្រូវរបស់អ្នក។

**ការព្រមានប្រាប់**

ប្រតិបត្តិការផ្លែតហ្វមច្រកល្ហកចូលមិនត្រឹមត្រូវអាចបណ្តាលឲ្យរងរបួសឬស្លាប់បាត់បង់ជីវិត។ ប្រតិបត្តិការត្រូវតែអនុវត្តតារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវ និងអនុវត្តតាមលិណែនាំ និងគោលការណ៍ទាំងអស់សម្រាប់គ្រឿងចក្រនិងផ្លែតហ្វមច្រកល្ហកចូលនេះ។

**ការព្រមានប្រាប់**

ការបញ្ឆេះម៉ាស៊ីនដោយចៃដន្យអាចធ្វើឲ្យអ្នកដែលធ្វើការនៅលើគ្រឿងចក្ររងរបួស ឬគ្រោះថ្នាក់ដល់ស្លាប់។

ដើម្បីចៀសវាងម៉ាស៊ីនបញ្ឆេះដោយចៃដន្យ ចូរផ្តាច់ខ្សែកាបអាគុយចេញពីតំណក្បាលអាគុយអវិជ្ជមាន (–)។ ចូររុំស្កុតជុំវិញផ្ទៃលោហៈចុងខ្សែកាបអាគុយដែលផ្តាច់ចេញទាំងអស់ ដើម្បីបង្ការការប៉ះជាមួយផ្ទៃលោហៈដទៃទៀត ដែលអាចបើកដំណើរការប្រព័ន្ធអគ្គិសនីម៉ាស៊ីន។

ប្តូរកុងតាក់ផ្តាច់អាគុយមកទីតាំងបិទ ហើយចាក់សោកុងតាក់ផ្តាច់អាគុយ ដោយប្រើសោសុវត្ថិភាព។

ដាក់ស្លាកសេចក្តីណែនាំពិសេស SEHS7332 "ហាមធ្វើប្រតិបត្តិការ" នៅកុងតាក់បញ្ឆេះនិងកន្លែងផ្តាច់អាគុយ ដើម្បីប្រាប់បុគ្គលិកថាគ្រឿងចក្រកំពុងដំណើរការ។

## សារសុវត្ថិភាព

ស្លាកព្រមាននៅក្នុងរូបភាពទី 1 អាចរកឃើញនៅក្នុងទីតាំងដូចជាប៉ាណ្ណូបរិធានស្ទង់ ឬកុងទ័របញ្ជា។ ប្រតិបត្តិករអាចមើលឃើញស្លាកព្រមាននេះយ៉ាងច្បាស់ក្នុងកំឡុងពេលប្រតិបត្តិការធម្មតានៃបរិក្ខារនេះ។




រូបភាព 1 g03356592

ស្លាក

**ការព្រមានប្រាប់**

ឧបករណ៍នេះត្រូវបានបំពាក់ជាមួយ Cat® ឧបករណ៍ទាក់ទងតំណផលិតផល។ នៅពេលដែលកិបអគ្គិសនីកំពុងត្រូវបានប្រើប្រាស់ធ្វើឲ្យផ្ទុះ, ឧបករណ៍ប្រេកង់វិទ្យុអាចរំខានដល់កិបអគ្គិសនីសម្រាប់ធ្វើឲ្យផ្ទុះ ដែលអាចបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ ឬបណ្តាលឲ្យស្លាប់។ ឧបករណ៍ទាក់ទងតំណផលិតផលគួរត្រូវបានផ្តាច់ក្នុងចម្ងាយដែលបានកំណត់ស្ថិតក្រោមតម្រូវការបទបញ្ញាមូលដ្ឋាន ឬថ្នាក់ជាតិដែលអនុវត្ត។ ក្នុងករណីមិនមានតម្រូវការបទបញ្ញា Caterpillar ផ្តល់យោបល់ឲ្យអ្នកប្រើប្រាស់អនុវត្តតាមការវាយតម្លៃគ្រោះថ្នាក់ផ្ទាល់ខ្លួនរបស់ពួកគេដើម្បីកំណត់ចម្ងាយប្រតិបត្តិការសុវត្ថិភាព។

តំបន់ផ្ទុះត្រូវបានកំណត់ជាតំបន់ដែលមានវត្ថុផ្ទុះក្នុងអំឡុងពេលផ្ទុក។ រួមបញ្ចូលគឺបរិវេណដែលបង្កើតឡើងដោយរណ្តៅផ្ទុះដែលបានផ្ទុក។

ប្រសិនបើវិធីសាស្ត្រដែលតម្រូវខាងក្រោមនេះជាវិធីសាស្ត្រដែលបានស្នើដើម្បីបិទឧបករណ៍ទំនាក់ទំនង Product Link របស់ Caterpillar ៖

- រុញកុងតាក់បិទវិទ្យុតំណភ្ជាប់ផលិតផលទៅបិទ។
- ផ្តាច់ឧបករណ៍ទាក់ទងតំណភ្ជាប់ផលិតផល Caterpillarពីប្រភពថាមពល។ សកម្មភាពនេះត្រូវបានអនុវត្តដោយផ្តាច់ខ្សែភ្លើងនៅវិទ្យុតំណភ្ជាប់ផលិតផល។

**សម្គាល់៖** ប្រសិនបើមិនបានដំឡើងកុងតាក់បិទវិទ្យុទេ ហើយឧបករណ៍នឹងប្រតិបត្តិការនៅជិតកន្លែងផ្ទុះ នោះអាចដំឡើងកុងតាក់បិទវិទ្យុបាន។ កុងតាក់នឹងអនុញ្ញាតឲ្យឧបករណ៍ទាក់ទងតំណភ្ជាប់ផលិតផល Caterpillar ត្រូវបានបិទដោយប្រតិបត្តិករពីបន្ទប់បញ្ជាបរិក្ខា។ សូមមើលសេចក្ដីណែនាំពិសេស REHS7339 សេចក្ដីណែនាំពិសេស REHS8850 សេចក្ដីណែនាំពិសេស REHS9111 សេចក្ដីណែនាំពិសេស SEHS0377 និងសេចក្ដីណែនាំពិសេស REHS9757 សម្រាប់ព័ត៌មានលម្អិត និងការណែនាំអំពីការដំឡើង។

## ស្លាកផ្សេងទៀត

ស្លាកព្រមាននៅក្នុងរូបភាពទី 2 អាចរកឃើញនៅក្នុងទីតាំងដូចជាប៉ាណ្ណូបរិធានស្ទង់ ឬកុងទ័របញ្ជា។ ប្រតិបត្តិករអាចមើលឃើញស្លាកព្រមាននេះយ៉ាងច្បាស់ក្នុងកំឡុងពេលប្រតិបត្តិការធម្មតានៃបរិក្ខារនេះ។




រូបភាព 2 g03356733

ស្លាកក្នុងរូបភាពទី 2 មានគោលបំណងប្រាប់ដល់ប្រតិបត្តិករថាបរិក្ខារនេះត្រូវបានបំពាក់ដោយឧបករណ៍បញ្ជូនឥតខ្សែ។ ដូច្នេះ ទិន្នន័យទាក់ទងនឹងបរិក្ខារ លក្ខខណ្ឌនៃបរិក្ខារ និងប្រតិបត្តិការនៃបរិក្ខារនេះកំពុងតែត្រូវបានបញ្ជូនដោយឧបករណ៍ទាក់ទង Caterpillar Product Link ទៅកាន់ Caterpillar ហើយនឹងត្រូវទាក់ទងទៅអតិថិជន និងអ្នកចែកចាយ Caterpillar ដោយកម្មវិធីទំនាក់ទំនងអ្នកប្រើប្រាស់។ ទិន្នន័យនេះត្រូវបានប្រើប្រាស់ដើម្បីបម្រើអតិថិជនឲ្យកាន់តែប្រសើរឡើង និងកែលម្អគ្រឿងចាក់ និង សេវាកម្ម Caterpillar។ ប្រអប់លេខព័ត៌មានដែលប្រើឧបករណ៍ទាក់ទង Caterpillar Product Link គឺត្រូវអនុវត្តទៅតាមច្បាប់ដែលអាចខុសគ្នាតាមទីកន្លែង។

សូមមើលសៀវភៅណែនាំអំពីប្រតិបត្តិការ និងការជួសជុលថែទាំ SEBU8832 ផ្នែក "ប្រតិបត្តិការ" និងសៀវភៅណែនាំអំពីប្រតិបត្តិការ និងជួសជុលថែទាំ SEBU8832 ផ្នែក "ការអនុវត្តបទបញ្ញត្តិ" សម្រាប់ព័ត៌មានបន្ថែម។

i07214817

# ព័ត៌មានអំពីគ្រោះថ្នាក់ទូទៅ

កូដ SMCS៖ 7606

**⚠ ការព្រមានប្រាប់**

**ហាមប្រតិបត្តិការ ឬធ្វើការងារលើគ្រឿងចក្រនេះ បើលោកអ្នកមិនបានអាន និងស្វែងយល់អំពីសេចក្ដីណែនាំនិងការព្រមាន ដែលមាននៅក្នុងសៀវភៅណែនាំប្រតិបត្តិការ និង ការថែទាំទេនោះ។ ការមិនអនុវត្តតាមសេចក្ដីណែនាំ ឬមិនបានយកចិត្តទុកដាក់លើការព្រមានទាំងនេះអាចបណ្ដាលឲ្យមានរបួសដល់រាងកាយ ឬស្លាប់បាន។ ទាក់ទងអ្នកចែកចាយ Caterpillar របស់អ្នកជំនួសឲ្យកូនសៀវភៅណែនាំ។ ការយកចិត្តទុកដាក់សមស្របគឺជាការទទួលខុសត្រូវរបស់អ្នក។**

## បុព្វកថា

ឯកសារនេះគឺជាការបន្ថែមដល់សៀវភៅណែនាំអំពីប្រតិបត្តិការ និងការជួលជុលថែទាំបរិក្ខារ។ ភ្ជាប់ឯកសារនេះជាអចិន្ត្រៃយ៍ទៅក្នុងសៀវភៅណែនាំស្ដីពីប្រតិបត្តិការ និងការជួសជុលថែទាំបរិក្ខារ។

## សេចក្ដីណែនាំ

ឯកសារនេះផ្ដល់ព័ត៌មានអំពីប្រតិបត្តិការនៃឧបករណ៍ទាក់ទងតំណភ្ជាប់ផលិតផល Caterpillar ។

ប្រតិបត្តិការបរិក្ខារ និងការជួសជុលថែទាំបរិក្ខារនេះមិនត្រូវធ្វើឡើងឡើយ ប្រសិនបើមិនទាន់បានអានសេចក្ដីណែនាំ និងការព្រមាននៅក្នុងសៀវភៅណែនាំអំពីប្រតិបត្តិការ និងការជួលជុលថែទាំបរិក្ខារនេះ និងមិនទាន់បានយល់អំពីការណែនាំ និងការព្រមាននេះទេនោះ។ ខ្លឹមសារនៃឯកសារនេះត្រូវតែយល់មុនពេលបរិក្ខារដែលបំពាក់ដោយឧបករណ៍ទាក់ទងរបស់ Caterpillar Product Link ដំណើរការ។

# ផ្នែកព័ត៌មានផលិតផល

# ព័ត៌មានអត្តសញ្ញាណ

i07214819

## ព័ត៌មានអំពីការផលិត

កូដ SMCS៖ 7606

### ឈ្មោះក្រុមហ៊ុននាំចូល និងក្រុមហ៊ុនផលិត EAC

អ្នកចែកចាយ៖ "Caterpillar Eurasia" Ltd.

ប្រទេសរុស្ស៊ី ក្រុងមូស្គូ 115035 Sadovnicheskaya Nab 75

ទូរស័ព្ទ៖ +7 (495) 2133340, ទូរសារ៖ +7 (495) 2133372,
អ៊ីមែល៖ cat_moscow@cat.com

ក្រុមហ៊ុនផលិត៖ Caterpillar Inc.

100 NE Adams Street Peoria, Illinois 61629 សហរដ្ឋអាមេរិក

ប្រទេសដើម - សហរដ្ឋអាមេរិក

### កាលបរិច្ឆេទផលិត

សញ្ញាសម្គាល់នៅលើឧបករណ៍ និង ឬ កញ្ចប់មានព័ត៌មានអំពីកាលបរិច្ឆេទនៃការផលិត ឬ តំណភ្ជាប់ទៅប្រភពព័ត៌មាននេះ។ ប្រសិនបើចាំបាច់ កាលបរិច្ឆេទនៃការផលិតអាចទទួលបានដោយលេខស៊េរីផលិតផលនោះដោយទាក់ទងទៅអ្នកចែកចាយរបស់អ្នកដែលទទួលបានការអនុញ្ញាត.

### អាណត្តិ និងលក្ខខណ្ឌនៃការផ្ទុក និងការដឹកជញ្ជូន

ផលិតផលនេះត្រូវបានខ្ចប់នៅក្នុងការវេចខ្ចប់សម្រាប់អតិថិជនរបស់ក្រុមហ៊ុនផលិត។ ផលិតផលនេះគួរតែរក្សាទុកនៅក្នុងស្តុករោងចក្រ និងលក្ខខណ្ឌនៃការផ្ទុកសម្រាប់កត្តាអាកាសធាតុនៃក្រុមទី 4 ស្របតាម GOST 15150-69 ។ នៅពេលផ្ទុក និងដឹកជញ្ជូន ត្រូវអនុវត្តតាមលក្ខខណ្ឌនៅលើស្លាកសញ្ញាព្រមាននៅលើប្រអប់។ មិនត្រូវអនុញ្ញាតឲ្យមានការប៉ះពាល់ដល់រូបរាង និងការប្រតិបត្តិរបស់ឧបករណ៍នៃឫម និងកាងទេ។

ការដឹកជញ្ជូនអាចធ្វើបានដោយរថយន្តដឹកជញ្ជូនដែលបានគ្របដណ្តប់គ្រប់ប្រទេស។ នៅពេលដឹកជញ្ជូនតាមអាកាស សូមធានាថា Product Linkdevice ត្រូវបានដឹកជញ្ជូននៅក្នុងបន្ទប់ដែលមានកំដៅបិទជិត។

### សកម្មភាពក្នុងករណីមានកំហុសបច្ចេកទេស

មុនពេលហៅកាន់អ្នកចែកចាយឲ្យជួសជុល សូមពិនិត្យមើលខ្សែភ្លើងអគ្គិសនីឲ្យបានត្រឹមត្រូវ ហើយបិទបើកថាមពលថ្មរបស់ឧបករណ៍។ ការបង្វិលថាមពលថ្មអាចធ្វើបានតាមរយៈ៖

- បិទការផ្តាច់ម៉ាស៊ីនមេ ហើយបើកវាវិញ
- ដកខ្សែតំណផលិតផលចេញពីឧបករណ៍ភ្ជាប់គ្រឿងចក្រ ហើយបន្ទាប់មក ដោតខ្សែឧបករណ៍ភ្ជាប់ឡើងវិញ។
- ផ្តាច់ខ្សែអគ្គិសនីអវិជ្ជមានពីស្ថានីយថ្មអវិជ្ជមានហើយបន្ទាប់មកភ្ជាប់ខ្សែអគ្គិសនីនោះឡើងវិញ។ ប្រសិនបើដំណោះស្រាយទាំងនេះមិនអាចជួយបាន សូមហៅទូរស័ព្ទដើម្បីទទួលបានសេវា។

i07214820

## ការអនុលោមតាមបញ្ញត្តិ

កូដ SMCS៖ 7606

---

សម្គាល់

ប្រអប់លេខព័ត៌មានដែលប្រើឧបករណ៍ទាក់ទង Caterpillar Product Link គឺត្រូវអនុវត្តទៅតាមតម្រូវការច្បាប់។ តម្រូវការផ្នែកច្បាប់អាចខុសគ្នាៗគ្នាទៅតាមទីកន្លែងផ្សេងគ្នា រួមទាំងការអនុញ្ញាតឲ្យប្រើប្រាស់ប្រេកង់វិទ្យុផងដែរ។ ការប្រើឧបករណ៍ទំនាក់ទំនង Caterpillar Product Link ត្រូវតែកំណត់ចំពោះទីតាំងទាំងនោះដែលបានបំពេញតាមតម្រូវការផ្នែកច្បាប់ទាំងអស់ក្នុងការប្រើឧបករណ៍ទាក់ទង Caterpillar Product Link និងបណ្តាញទំនាក់ទំនង។

ប្រសិនបើបរិក្ខារដែលបានបំពាក់ជាមួយឧបករណ៍ប្រាស្រ័យទាក់ទង Caterpillar Product Link ស្ថិតក្នុងទីកន្លែង ឬក៏ផ្លាស់ប្តូរទីកន្លែងទៅកន្លែងមួយដែល (i) មិនបានបំពេញតាមតម្រូវការច្បាប់ ឬ (ii) ការបញ្ជូន ឬការដំណើរការព័ត៌មាននោះ កាត់ទីកន្លែងច្រើនដែលមិនស្របច្បាប់ Caterpillar សូមប្រកាសបដិសេធនូវការទទួលខុសត្រូវទាំងឡាយដែលពាក់ព័ន្ធនឹងការខកខានក្នុងការអនុលោមតាមច្បាប់ ហើយ Caterpillar អាចផ្តាច់ការបញ្ជូនព័ត៌មានពីបរិក្ខារនោះ។

ចូរប្រឹក្សាជាមួយអ្នកចែកចាយផលិតផល Cat របស់លោកអ្នក ប្រសិនបើមានសំណួរ ឬកង្វល់អំពីប្រតិបត្តិការប្រព័ន្ធ Product Link នៅក្នុង ប្រទេសជាក់លាក់។

---

### កំណត់សម្គាល់វិទ្យុ PL042

#### កំណត់សម្គាល់ FCC

ឧបករណ៍នេះអនុលោមតាមផ្នែកទី 15 នៃបទបញ្ញត្តិ FCC ។ ប្រតិបត្តិការគឺស្ថិតនៅក្រោមលក្ខខណ្ឌពីរខាងក្រោម៖

- ឧបករណ៍នេះអាចនឹងមិនបង្កឲ្យមានការរំខានវិទ្យុទាក់ទងដែលបង្កគ្រោះថ្នាក់ឡើយ។
- ឧបករណ៍នេះត្រូវតែទទួលយកការរំខានទាំងឡាយដែលបានទទួល រួមទាំងការរំខានដែលអាចបង្ក ឲ្យមានដំណើរការមិនស្រួល។

បរិក្ខារនេះត្រូវបានសាកល្បង ហើយត្រូវបានរកឃើញថាបានអនុលោមតាមដែនកំណត់ឧបករណ៍ឌីជីថលថ្នាក់ B តាមផ្នែកទី 15 នៃបទបញ្ញត្តិ FCC ។ ដែនកំណត់ទាំងនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការការពារសមស្របចំពោះការរំខានវិទ្យុទាក់ទងដែលបង្កគ្រោះថ្នាក់នៅក្នុងការដំឡើងលំនៅដ្ឋាន។ ឧបករណ៍នេះបង្កើត ប្រើប្រាស់ និងអាចបញ្ចេញថាមពលប្រេកង់វិទ្យុសកម្ម ហើយប្រសិនបើមិនបានដំឡើង និងប្រើប្រាស់តាមសេចក្តីណែនាំទេនោះ អាចបណ្តាលឲ្យមានការរំខានដល់ដល់ទំនាក់ទំនងវិទ្យុ។ ទោះយ៉ាងណាក៏ដោយ មិនមានការធានាថាការរំខានវិទ្យុសកម្មនោះនឹងមិនកើតឡើងនៅក្នុងការដំឡើងជាក់លាក់ឡើយ។ ប្រសិនបើបរិក្ខារនេះបណ្តាលឲ្យមានការរំខានដែលបង្កគ្រោះថ្នាក់ដល់ការទទួលយកវិទ្យុ ឬទូរទស្សន៍ដែលអាចកំណត់បានដោយការបិទ និងបើកបរិក្ខារ អ្នកប្រើប្រាស់ត្រូវបានលើកទឹកចិត្តឲ្យព្យាយាមកែប្រែការរំខានដោយវិធានការមួយ ឬច្រើនដូចខាងក្រោម៖

- ប្តូរទិស ឬប្តូរទីតាំងអង់តែនទទួល
- បង្កើនគម្លាតរវាងបរិក្ខារ និងឧបករណ៍ទទួល
- ភ្ជាប់គ្រឿងបរិក្ខារនេះទៅក្នុងព្រីភ្លើងមួយនៅលើសៀគ្វីខុសពីកន្លែងដែលឧបករណ៍ទទួលបាន តភ្ជាប់
- ពិគ្រោះជាមួយអ្នកចែកចាយ ឬអ្នកបច្ចេកទេសវិទ្យុ / ទូរទស្សន៍ដែលមានបទពិសោធន៍សម្រាប់ជំនួយ

ការផ្លាស់ប្តូរ ឬការកែប្រែឧបករណ៍នេះដោយគ្មានការអនុញ្ញាតពីក្រុមហ៊ុន Caterpillar អាចនឹងធ្វើឲ្យបាត់បង់ សិទ្ធិប្រើប្រាស់ឧបករណ៍នេះ។

## កំណត់សម្គាល់ឧស្សាហកម្មកាណាដាចំពោះអ្នកប្រើប្រាស់

ប្រតិបត្តិការគឺស្ថិតនៅក្រោមលក្ខខណ្ឌពីរខាងក្រោម៖

- ឧបករណ៍នេះអាចបង្កឲ្យមានការរំខាន

- ឧបករណ៍នេះត្រូវតែទទួលយកការរំខានទាំងឡាយ រួមមានការរំខានដែលអាចបណ្ដាល ឲ្យមាន ដំណើរការឧបករណ៍មិនស្រួលៗ

## ការដាក់សញ្ញាសម្គាល់វិញ្ញាបនបត្រ PL042

| COUNTRIES | Labeling Requirements | Package/User Manual Labeling | Comments |
|---|---|---|---|
| COSTA RICA | New requirements coming | | **New requirements coming**<br>**Previously local rep to apply SUTEL mark/label during importation** |
| INDONESIA | 51763/SDPPI/2017 | Product, user manual, or packaging<br>(Easily seen by customs) | |
| JAPAN | R 003-170036<br>T D170023003 | Mark can be on product, packaging, or user manual | Minimum 5mm diameter. If product volume is 100cc or less, diameter can be 3mm |
| NIGERIA | "Connection and use of this Communications equipment is permitted by the Nigerian Communications Commission" | If not marked on product, must be in user manual.<br>Can be also marked on package | Label must be approved by the Commission<br>Height 2mm minimum |
| QATAR | ictQATAR<br>Type Approval reg. No:<br>CRA/SA/2017/R-6426 | When marked on package, minimum dimensions shall be doubled | **Labelling is voluntary, as of 7/18/17: Labelling is not required, not enforced.**<br>Height 3mm minimum |
| SINGAPORE | Complies with IDA Standards<br>DB105771 | Product, user manual, or packaging | DB105771 is CAT's Dealer License |
| THAILAND | "This telecommunication equipment conforms to NTC technical requirement" | Package or user manual | Add compliance statement to manual. Label is optional for SDoC certifications |
| UNITED ARAB EMIRATES | TRA REGISTERED No: ER47254/16<br>DEALER No: DA0130583/14 | When marked on package, minimum dimensions shall be doubled | Height 2mm minimum, "TRA" 3mm minimum |

រូបភាព 3
g06256363

## កំណត់សម្គាល់ប្រធានបណ្តាញ PLE702

**⚠ ការព្រមានប្រាប់**

ត្រូវប្រុងប្រយ័ត្នក្នុងការកាន់យួរអាគុយលីស្យូម។

អាគុយអាលុយមីញ៉ូមមិនមែនជាគ្រឿងប្រើប្រាស់បានយូរអង្វែងនោះទេ។

ការរងរបួសផ្ទាល់ខ្លួនអាចបណ្តាលមកពីការផ្ទុះថ្ម ឬអាគុយ។

ត្រូវតែមានការប្រុងប្រយ័ត្ន ព្រោះមានហានិភ័យនៃការផ្ទុះប្រសិនបើអាគុយត្រូវបានជំនួសដោយ ប្រភេទមិនត្រឹមត្រូវ។

ចូរកុំបោះថ្មចោលទៅក្នុងភ្លើង។ អាគុយអាចនឹងផ្ទុះ និងបញ្ចេញ សារធាតុគីមីឆេះ។

បោះចោលអាគុយដែលប្រើហើយតាមច្បាប់ជាតិ និងច្បាប់តំបន់។

i07214821

# សេចក្តីប្រកាសអំពីអនុលោមភាព

កូដ SMCS៖ 7606

## សេចក្តីប្រកាស EU របស់សហភាពអឺរ៉ុបស្តីពីអនុលោមភាព PL042

តារាងទី 1

CATERPILLAR®

សេចក្តីប្រកាស EU ស្តីពីអនុលោមភាព

ការចេញសេចក្តីប្រកាសនៃអនុលោមភាពនេះស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អ្នកផលិត។

ហត្ថលេខាខាងក្រោមនេះ តំណាងឲ្យក្រុមហ៊ុនផលិត៖

CATERPILLAR INC

100 N.E. Adams Street

Peoria, IL 61629

USA

សូមបញ្ជាក់ថាផលិតផល ឧបករណ៍ដែលបានពិពណ៌នានេះ៖

ឃីហោ៖ ម៉ូដែល Caterpillar ៖ PL042

លេខផ្នែក៖ 514-7505

លេខផ្នែកអង់តែន៖ ខាងក្នុង

គឺអនុលោមតាមច្បាប់សុខដុមនីយកម្មរបស់សហភាពដែលពាក់ព័ន្ធ៖

សេចក្តីណែនាំ 2014/53/EU

សេចក្តីណែនាំ 2011/65/EU

(បន្ត)

(តារាង 1, បន្ត)

អនុលោមភាពត្រូវបានបង្ហាញដោយអនុវត្តតាមតម្រូវការជាធរមាននៃឯកសារដូចខាងក្រោម៖

នីតិវិធីវាយតម្លៃអនុលោមភាព៖ _______ ឧបសម្ព័ន្ធ II, ___X___ ឧបសម្ព័ន្ធ III, _______ឧបសម្ព័ន្ធ IV

| | | |
|---|---|---|
| 2014/53/EU ៖ RED | LVD (Sec 3.1a) ៖ | EN60950-1:2006 + A11:2009+ A1:2010 + A12:2011 + A2:2013 |
| | | EN 62311:2008 |
| | EMC (Sec 3.1b) ៖ | EN 301 489-1 V2.1.1 (R&TTE), V2.2.0 (ក្រហម) |
| | | EN 301 489-19: V2.1.0 (RED) (ក្រហម) |
| | RF (Sec 3.2) | EN 301 511:V9.0.2, V12.5.1 (ក្រហម) |
| | | EN 301 908–1:V6.2.1, V11.1.1 (ក្រហម) |
| | | EN 301 908–2 V11.1.1 (ក្រហម) |
| | | EN 303 413: V1.1.0 (ក្រហម) |
| 2011/65/EU ៖ | | EN 50581:2012 |

| | |
|---|---|
| ឈ្មោះអង្គភាពដែលបានជូនដំណឹង៖ | TUV SUD BABT |
| លេខអង្គភាពដែលបានជូនដំណឹង៖ | 0168 |
| វិញ្ញាបនបត្រត្រួតពិនិត្យលេខ៖ | BABT-RED000457 i01.01 |




រូបភាព 4 g06256346

# សេចក្តីប្រកាស EU របស់សហភាពអឺរ៉ុបស្តីពីអនុលោមភាព PLE702

តារាងទី 2

CATERPILLAR®

សេចក្តីប្រកាស EU ស្តីពីអនុលោមភាព

ការចេញសេចក្តីប្រកាសនៃអនុលោមភាពនេះស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អ្នកផលិត។

ហត្ថលេខាខាងក្រោមនេះ តំណាងឲ្យក្រុមហ៊ុនផលិត៖

CATERPILLAR INC

100 N.E. Adams Street

Peoria, IL 61629

USA

(បន្ត)

(តារាង 2, បន្ត)

សូមបញ្ជាក់ថាផលិតផល ឧបករណ៍ដែលបានពិពណ៌នានេះ៖

យីហោ៖ Caterpillar

ម៉ូដែល៖ PLE702

លេខផ្នែក៖ 494-6472

494-6473

គឺអនុលោមតាមច្បាប់សុខដុមនីយកម្មរបស់សហភាពដែលពាក់ព័ន្ធ៖

សេចក្តីណែនាំ 2014/30/EU

សេចក្តីណែនាំ 2011/65/EU

អនុលោមភាពត្រូវបានបង្ហាញដោយអនុវត្តតាមតម្រូវការជាធរមាននៃឯកសារដូចខាងក្រោម៖

| | | |
|---|---|---|
| 2014/30/EU៖ | EMC | EN13309:2010 |
| | | EN ISO 14982:2009 |

នីតិវិធីវាយតម្លៃអនុលោមភាព៖ ___X___ ឧបសម្ព័ន្ធ II, _______ ឧបសម្ព័ន្ធ III, _______ឧបសម្ព័ន្ធ IV

| | | |
|---|---|---|
| សេចក្តីណែនាំ 2011/65/EU | RoHS | EN 50581:2012 |
| ស្តង់ដារផ្សេងៗបានអនុវត្ត៖ | | ISO13766:2006 |
| | | EN 61000-4-8:2016 |
| | | EN 61000-4-6:2003 |
| | | EN 61000-4-4:2016 |
| | | EN 61000-4-5:2014 |

**Signature:**

**Name: Michael A Caruthers** **Title: Engineering Manager**

**Place: Peoria, Illinois, USA** **Date: 02Nov2017**

រូបភាព 5 g06256602

# ផ្នែកប្រតិបត្តិការ

# ប្រតិបត្តិការ

i07214822

## ទិដ្ឋភាពទូទៅប្រព័ន្ធ

កូដ SMCS៖ 7606

**កំណត់សម្គាល់៖** បរិក្ខាររបស់យើងអាចត្រូវបានបំពាក់ដោយឧបករណ៍ប្រាស្រ័យទាក់ទង Caterpillar Product Link ។

ឧបករណ៍ទាក់ទងតំណផលិតផល Caterpillar ប្រើប្រាស់បច្ចេកវិទ្យាចល័ត និង/ឬផ្កាយរណប ដើម្បីទាក់ទងជាមួយព័ត៌មានអំពីបរិក្ខា។ ព័ត៌មាននេះត្រូវបានទំនាក់ទំនងទៅ Caterpillar, តំណាងលក់ Cat និង អតិថិជន Caterpillar។ ឧបករណ៍ទាក់ទងតំណផលិតផល Caterpillar មានឧបករណ៍ទទួលផ្កាយរណបនៃប្រព័ន្ធកំណត់ទីតាំងសកល (GPS) មួយ។

**កំណត់សម្គាល់៖** ឧបករណ៍ Product Link ទាំងអស់ត្រូវតែស្ថិតនៅចម្ងាយលើសពី 200 មម (7,874 អ៊ីង) ពីប្រតិបត្តិករម៉ាស៊ីនដើម្បីអនុលោមតាមបទបញ្ញត្តិ FCC សម្រាប់សុវត្ថិភាពរាងកាយមនុស្ស។

### ការផ្សព្វផ្សាយទិន្នន័យ

ទិន្នន័យទាក់ទងនឹងបរិក្ខារនេះ លក្ខខណ្ឌនៃបរិក្ខារ និងប្រតិបត្តិការនៃបរិក្ខារនេះកំពុងតែត្រូវបានបញ្ជូនដោយឧបករណ៍ទាក់ទង Caterpillar Product Link ទៅកាន់ Caterpillar ហើយបានទាក់ទងទៅអតិថិជន និងអ្នកចែកចាយ Caterpillar ដោយកម្មវិធីទំនាក់ទនងអ្នកប្រើប្រាស់។ ទិន្នន័យនេះត្រូវបានប្រើប្រាស់ដើម្បីបម្រើអតិថិជនឲ្យកាន់តែប្រសើរឡើង និងកែលម្អគ្រឿងចាក់ និង សេវាកម្ម Caterpillar។ ព័ត៌មានដែលបានបញ្ជូនរួមមាន៖ លេខសេរីបរិក្ខារ ទីតាំងបរិក្ខារ និងទិន្នន័យប្រតិបត្តិការ ដូចជា៖ កូដកំហុស ទិន្នន័យនៃការបញ្ចេញឧស្ម័នពុល ការប្រើប្រាស់ប្រេងឥន្ធនៈ ម៉ោងនៅលើកុងទ័រប្រើប្រាស់ លេខកំណែសូហ្វែរ និង ហាដវែរ ព្រមទាំងគ្រឿងភ្ជាប់ដែលបានដំឡើង។

Caterpillar និង/ឬ អ្នកចែកចាយ Cat អាចប្រើប្រាស់ព័ត៌មាននេះសម្រាប់គោលបំណងផ្សេងៗ។ សូមមើលបញ្ជីខាងក្រោមសម្រាប់លទ្ធភាពនៃការប្រើប្រាស់៖

- ការផ្តល់សេវាកម្មជូនអតិថិជន និង/ឬបរិក្ខារ
- ការត្រួតពិនិត្យ ឬ ការថែទាំប្រព័ន្ធតំណផលិតផល
- ត្រួតពិនិត្យសុខភាព ឬការបំពេញការងារនៃបរិក្ខារ
- ការជួយថែទាំបរិក្ខា និង/ឬ កែលម្អប្រសិទ្ធភាពនៃបរិក្ខា
- ការវាយតម្លៃ ឬការកែលម្អគ្រឿងចាក់ និងសេវាកម្ម Caterpillar
- ការអនុលោមតាមតម្រូវការច្បាប់ និងការបញ្ជារបស់តុលាការដែលមានសុពលភាព
- ការធ្វើការស្រាវជ្រាវទីផ្សារ
- ការផ្តល់ជូនអតិថិជននូវគ្រឿងចាក់ និង សេវាកម្មថ្មីៗ

Caterpillar អាចចែករំលែកព័ត៌មានដែលបានប្រមូលខ្លះ ឬ ទាំងអស់ជាមួយនឹងក្រុមហ៊ុនសម្ពន្ធរបស់ Caterpillar អ្នកចែកចាយ និងតំណាងដែលទទួលសិទ្ធិ។ Caterpillar នឹងមិនលក់ ឬជួលព័ត៌មានដែលបានប្រមូលទៅឲ្យភាគីទីបីណាមួយឡើយ ហើយនឹងអនុវត្តវិធានការសមស្របដើម្បីរក្សាឲ្យព័ត៌មានទាំងនោះមានសុវត្ថិភាព។ Caterpillar ទទួលស្គាល់ និងគោរពភាពឯកជនរបស់អតិថិជន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកចែកចាយ Cat ក្នុងស្រុករបស់អ្នក។

### ប្រតិបត្តិការនៅកន្លែងផ្ទុះសម្រាប់ វិទ្យុតំណផលិតផល

**⚠ ការព្រមានប្រាប់**

**ឧបករណ៍នេះត្រូវបានបំពាក់ជាមួយ Cat® ឧបករណ៍ទាក់ទងតំណផលិតផល។ នៅពេលដែលកិបអគ្គិសនីកំពុងត្រូវបានប្រើប្រាស់ធ្វើឲ្យផ្ទុះ, ឧបករណ៍ប្រេកង់វិទ្យុអាចរំខានដល់កិបអគ្គិសនីសម្រាប់ធ្វើឲ្យផ្ទុះ ដែលអាចបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ ឬបណ្តាលឲ្យស្លាប់។ ឧបករណ៍ទាក់ទងតំណផលិតផលគួរត្រូវបានផ្តាច់ក្នុងចម្ងាយដែលបានកំណត់ស្ថិតក្រោមតម្រូវការបទបញ្ញាមូលដ្ឋាន ឬថ្នាក់ជាតិដែលអនុវត្ត។ ក្នុងករណីមិនមានតម្រូវការបទបញ្ញា Caterpillar ផ្តល់យោបល់ឲ្យអ្នកប្រើប្រាស់អនុវត្តតាមការវាយតម្លៃគ្រោះថ្នាក់ផ្ទាល់ខ្លួនរបស់ពួកគេដើម្បីកំណត់ចម្ងាយប្រតិបត្តិការសុវត្ថិភាព។**

---

ប្រសិនបើវិធីសាស្ត្រដែលតម្រូវខាងក្រោមនេះជាវិធីសាស្ត្រដែលបានស្នើដើម្បីបិទឧបករណ៍ទំនាក់ទំនង Product Link របស់ Caterpillar ៖

- រុញកុងតាក់បិទវិទ្យុតំណភ្ជាប់ផលិតផលទៅបិទ។
- ផ្តាច់ឧបករណ៍ទាក់ទងតំណភ្ជាប់ផលិតផល Caterpillarពីប្រភពថាមពល។ សកម្មភាពនេះត្រូវបានអនុវត្តដោយផ្តាច់ខ្សែភ្លើងនៅវិទ្យុតំណភ្ជាប់ផលិតផល។

**ចំណាំ៖** បើមិនមានកុងតាក់បិទវិទ្យុត្រូវបានដំឡើង ហើយបរិក្ខានឹងប្រតិបត្តិការនៅជិតកន្លែងផ្ទុះ កុងតាក់បិទវិទ្យុតំណភ្ជាប់ផលិតផលអាចត្រូវបានដំឡើងលើបរិក្ខានោះ។ កុងតាក់នឹងអនុញ្ញាតឲ្យឧបករណ៍ទាក់ទងតំណភ្ជាប់ផលិតផល Caterpillar ត្រូវបានបិទដោយប្រតិបត្តិករពីបន្ទះបញ្ជាបរិក្ខា។

លក្ខណៈនៃឧបករណ៍ទាក់ទងតំណផលិតផល Caterpillarខាងក្រោមត្រូវបានផ្តល់ជូនដើម្បីជួយធ្វើការវាយតម្លៃអំពីគ្រោះថ្នាក់ដែលពាក់ព័ន្ធ និងធានាអំពីអនុលោមភាពតាមបទបញ្ញត្តិក្នុងស្រុកទាំងអស់៖

តារាងទី 3

| លក្ខណៈពិសេសឧបករណ៍បញ្ជូនវិទ្យុ | | |
|---|---|---|
| **ម៉ូដែលវិទ្យុ (អតិបរមា)** | **ប្រេកង់ឧបករណ៍បញ្ជូន** | **ថាមពលឧបករណ៍បញ្ជូនចន្លោះ** |

(បន្ត)

(តារាង 3, បន្ត)

| | | |
|---|---|---|
| PL042 | 824 MHz - 849 MHz | 0.5W typical, 2W max |
| | 880 MHZ - 915 MHz | |
| | 1710 MHz - 1755 MHz | |
| | 1850 MHz - 1910 MHz | |
| | 1920 MHz - 1980 MHz | |
| | 2110 MHz - 2170 MHz | |

ពិគ្រោះយោបល់ជាមួយអ្នកចែកចាយ Cat របស់អ្នកប្រសិនបើមានសំណួរ។

ព័ត៌មានអំពីប្រតិបត្តិការ រូបសណ្ឋាន និងការរកដំណោះស្រាយបញ្ហា សម្រាប់ឧបករណ៍ប្រាស្រ័យទាក់ទង Caterpillar Product Link គឺអាចរកបានក្នុងប្រតិបត្តិការប្រព័ន្ធ ការរកដំណោះស្រាយបញ្ហា ការធ្វើតេស្ត និងការលៃតម្រូវ M0076820 ។

# លិបិក្រម

## ក

ការអនុលោមតាមបទបញ្ញត្តិ....7
ការដាក់សញ្ញាសម្គាល់វិញ្ញាបនបត្រ PL042....9
កំណាត់សម្គាល់វិទ្យុ PL042....7
កំណាត់សម្គាល់ប្រធានបណ្ដាញ PLE702....11

## គ

តារាងមាតិកា....3

## ទ

ទិដ្ឋភាពរួមប្រព័ន្ធ....14
ការផ្សព្វផ្សាយទិន្នន័យ....14
ប្រតិបត្តិការនៅកន្លែងផ្ទុះសម្រាប់វិទ្យុតំណាងលិតផល....14

## ប

បុព្វកថា....4
ការថែទាំជួសជុល....4
ប្រតិបត្តិការ....4
ព័ត៌មានអំពីឯកសារ....4
សុវត្ថិភាព....4
ប្រតិបត្តិការ....14

## ផ

ផ្នែកប្រតិបត្តិការ....14
ផ្នែកព័ត៌មានផលិតផល....7
ផ្នែកសុវត្ថិភាព....5

## ព

ព័ត៌មានសុវត្ថិភាពសំខាន់ៗ....2
ព័ត៌មានអត្តសញ្ញាណ....7
ព័ត៌មានអំពីគ្រោះថ្នាក់ទូទៅ....6
បុព្វកថា....6
សេចក្ដីណែនាំ....6
ព័ត៌មានអំពីផលិតកម្ម....7
កាលបរិច្ឆេទផលិត....7
ឈ្មោះក្រុមហ៊ុននាំចេញ និងក្រុមហ៊ុនផលិត EAC....7
សកម្មភាពក្នុងករណីដែលមានកំហុសបច្ចេកទេស....7
អាណត្តិ និងលក្ខខណ្ឌនៃការស្តុកទុក និងការដឹកជញ្ជូន....7

## ស

សញ្ញា និងស្លាកសញ្ញាសុវត្ថិភាព....5
រូបសញ្ញាផ្សេងទៀត....6
សារសុវត្ថិភាព....5
សេចក្ដីប្រកាសស្ដីពីអនុលោមភាព....11
សេចក្ដីប្រកាស EU របស់សហភាពអឺរ៉ុបស្ដីពីអនុលោមភាព PL042....11
សេចក្ដីប្រកាស EU របស់សហភាពអឺរ៉ុបស្ដីពីអនុលោមភាព PLE702....12

# ព័ត៌មានស្ដីពីគ្រឿងចក្រ និងអ្នកចែកចាយ

កំណត់ចំណាំ៖សម្រាប់ទីតាំងសម្គាល់ផ្លាកលេខគ្រឿងចក្រ សូមមើលផ្នែក "ព័ត៌មានអំពីការកំណត់អត្តសញ្ញាណគ្រឿងចក្រ" នៅក្នុងកូនសៀវភៅណែនាំដំណើរការ និងការថែទាំជួសជុល។

**កាលបរិច្ឆេទប្រគល់៖** ______________________________

## ព័ត៌មានស្ដីពីគ្រឿងចក្រ

ម៉ូដែល៖ ______________________________

លេខអត្តសញ្ញាណគ្រឿងចក្រ៖ ______________________________

លេខសេរីម៉ាស៊ីន៖ ______________________________

លេខសេរីប្រអប់លេខ៖ ______________________________

លេខសេរីម៉ាស៊ីនភ្លើង៖ ______________________________

លេខសេរីគ្រឿងភ្ជាប់៖ ______________________________

ព័ត៌មានស្ដីពីគ្រឿងភ្ជាប់៖ ______________________________

លេខគ្រឿងបរិក្ខារអតិថិជន៖ ______________________________

លេខគ្រឿងបរិក្ខារអ្នកចែកចាយ៖ ______________________________

## ព័ត៌មានអំពីអ្នកចែកចាយ

ឈ្មោះ៖ ______________________________ សាខា៖ ______________________________

អាសយដ្ឋាន៖ ______________________________

______________________________

______________________________

| | ទំនាក់ទំនងអ្នកចែកចាយ | លេខទូរស័ព្ទ | ម៉ោង |
|---|---|---|---|
| ការលក់៖ | | | |
| គ្រឿងបន្លាស់៖ | | | |
| សេវាកម្ម៖ | | | |

M0088349

©2017 Caterpillar

រក្សាសិទ្ធិគ្រប់យ៉ាង

CAT, CATERPILLAR ឡូហ្គោរៀងៗខ្លួនរបស់ពួកគេ "Caterpillar Yellow" និង ទម្រង់នៃកម្មសិទ្ធិបញ្ញា POWER EDGE ក៏ដូចជាអត្តសញ្ញាណសាជីវកម្ម និងលេខផលិតផលដែលប្រើនៅក្នុងនេះ គឺជាពាណិជ្ជកម្មសញ្ញានៃក្រុមហ៊ុន Caterpillar ហើយមិនអាចនឹងមានការប្រើប្រាស់ដោយគ្មានការអនុញ្ញាតឡើយ។